# កម្មវិធីសន្ទនាតាមវិទ្យុ

## “ស្វែងយល់ពីច្បាប់សំខាន់ៗដែលជាឧបករណ៍លើកកំពស់  អភិបាលកិច្ចល្អ”

*សម្រាប់ថ្ងៃច័ន្ទ ទី ១៦ ខែ ឧសភា ឆ្នាំ ២០១១*

**ចំនួនអត្ថបទ:** ប្រមាណ ៣០០ អត្ថបទ

*ដំណឹងសំខាន់ៗប្រចាំសប្តាហ៍:* *០៣ ដំណឹង*

### *១. មន្ត្រីចំនួន ៣៧០នាក់ ពុំទាន់បានប្រកាសទ្រព្យសម្បត្តិ នៅឡើយ*

តាមរយៈការចុះផ្សាយរបស់សារពត៌មាននានាបានឱ្យដឹងថា ឯកឧត្តម ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រី និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ បានថ្លែងថាមានមន្ត្រីចំនួន៣៧០នាក់ មិនទាន់បានប្រកាសទ្រព្យសម្បត្តិតាមការកំណត់នៅឡើយ ដោយសារមូលហេតុផ្សេងៗ។ ឯកឧត្តម ឱម យ៉ិនទៀង បានថ្លែងដូច្នេះក្នុងឱកាសពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារស្នាប័នប្រឆាំងអំពើពុករលួយ កាលពីព្រឹកថ្ងៃទី១១ ឧសភា ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ តាមកាសែត***រស្មីកម្ពុជា*** ចេញផ្សាយថ្ងៃទី២០ ឧសភា បានឱ្យដឹងថា ឯកឧត្តម ឱម យ៉ិនទៀង បានមានប្រសាសន៍ក្នុងឱកាសនោះថា ការបញ្ចប់ការងារប្រកាសទ្រព្យសម្បត្តិនិងបំណុលដែលមានអ្នកជាប់កាតព្វកិច្ចចំនួន ២៤.៨៣៧ នាក់ត្រូវប្រកាសព្រទ្យសម្បត្តិ គឺបានមកប្រកាសចំនួន*៩៩*ភាគរយហើយ នៅសល់មនុស្សចំនួន ៣៧០នាក់ទៀត ដែលពុំទាន់បានមកប្រកាស ដោយមូលហេតុអ្នកខ្លះមានជាប់បេសកកម្មទៅឆ្ងាយ អ្នកខ្លះជាប់សិក្សារយៈពេលវែង ខ្លះមានជំងឺ និងមួយចំនួនទៀតអាចដោយសារមានឈ្មោះជាន់គ្នានៅតាមក្រសួងស្ថាប័នរបស់រដ្ឋ។ ដូចនេះ តួលេខនេះពុំទាន់អាចថាជាតួលេខចុងក្រោយនោះទេ។ ជាមួយគ្នានោះ ***រស្មីកម្ពុជា*** ក៏បានដកស្រង់ផងដែរនូវប្រសាសន៍របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលបានថ្លែងថា កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ គឺបានស្តែងឡើងយ៉ាងច្បាស់តាមរយៈការបង្កើត និងការអនុវត្តន៏ច្បាប់ប្រឆាំងអំពើពុលរលួយ និងសកម្មភាពអាទិភាពជាច្រើនទៀតដែលមានចែងយ៉ាងច្បាស់នៅក្នុងផែនការសកម្មភាពអភិបាលកិច្ចល្អ គឺសុទ្ធតែទាក់ទងដោយផ្ទាល់ទៅនឹងការលុបបំបាត់ដល់ឫសគល់នៃអំពើពុករលួយ និងថា កិច្ចការប្រឆាំងអំពើពុករលួយគឺជាយុទ្ធសាស្ត្រមួយ ក្នុងចំណោមយុទ្ធសាស្ត្រអភិវឌ្ឍន៏ប្រទេសរបស់រាជរដ្ឋាភិបាល។ ទោះជាកិច្ចការនេះប្រកបដោយការលំបាកយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលប្តេជ្ញាទប់ស្កាត់ឱ្យបាន ក្នុងប្រយោជន៏ដើម្បីកសាងសេដ្ឋកិច្ចមួយដែលមានតម្លាភាព និងនិរន្តភាព។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានចាត់ទុកពិធីដាក់សម្ពោធឱ្យប្រើប្រាស់អគារស្ថាប័នប្រឆាំងអំពើពុករលួយថាជាសក្ខីភាពបង្ហាញឱ្យឃើញពីលទ្ធផលសម្រេចបាន និងឆន្ទៈដ៏ធំធេងរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងប្រទេសទាំងមូល ហើយនេះក៏ជាព្រឹត្តការណ៏ថ្មីមួយ បង្ហាញឱ្យអ្នករិះគន់ទាំងអស់យល់កាន់តែច្បាស់ពីជំហរយុទ្ធសាស្ត្រដ៏ជាក់ច្បាស់របស់រាជរដ្ឋាភិបាលផងដែរ។

## ២. រកឃើញផ្ទៃដីព្រៃលិចទឹកជាង ៣០០ ហិកតាដែលចៅហ្វាយស្រុកតំបែរ លក់ឱ្យក្រុមហ៊ុន

តាមកាសែត ***រស្មីកម្ពុជា*** ចេញផ្សាយថ្ងៃទី១០ ឧសភា បានឱ្យដឹងថា ខណ្ឌរដ្ឋបាលជលផលកំពង់ចាមបានរកឃើញផ្ទៃដីលិចទឹកចំនួន ៣៨៦ហិកតា នៅភូមិ ជីទ្រុន ឃុំត្រពាំងព្រីង ស្រុកតំបែរ ខេត្តកំពង់ចាម ត្រូវបានអភិបាលស្រុកលក់ទៅឱ្យក្រុមហ៊ុនមួយ ហើយក្រុមហ៊ុននោះកំពុងធ្វើការឈូសឆាយយកដីធ្វើចំការដំាំជក់។ ក៏ប៉ុន្តែមន្ត្រីជលផលបាននិយាយថា ដីនៅតំបន់នោះគឺជាដីវិនិយោគរបស់ក្រុមហ៊ុនចិនមួយដែលមានឈ្មោះផ្សេងទៅវិញ។ បន្ទាប់ពីព័ត៌មានខាងលើត្រូវបានបែកធ្លាយ ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះបាននាំគ្នាសំណូមពរដល់ក្រសួងកសិកម្ម និង សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជួយអន្តរាគមន៍ដើម្បីរក្សាដីតំបន់នោះទុកជាដែននេសាទរួម ព្រោះតំបន់នោះគឺជាបឹងធម្មជាតិតាំងពីសម័យបុរាណ។ ក្រុមប្រជាពលរដ្ឋបានលើកឡើងថា អាជ្ញាធរឃុំ បានឱ្យពួកគាត់ផ្តិតមេដៃទទួលយកប្រាក់ក្នុងមួយគ្រួសារ៣០០ដុល្លារ ដោយពួកគាត់ក៏មិនបានយល់ថាខាងអាជ្ញាធរបានឃុបឃិតគ្នាលក់ដីព្រៃលិចទឹកនោះទៅឱ្យក្រុមហ៊ុនឯកជនឡើយ។ ឆ្លើយតបនឹងបញ្ហានេះ លោកអភិបាលស្រុកតំបែរបានប្រាប់ ***រស្មីកម្ពុជា*** ថាពិតជាបានលក់ដីនៅតំបន់នោះមែនបន្ទាប់ពីមានការព្រមព្រៀងពីប្រជាពលរដ្ឋនៅភូមិជីទ្រុន ម្យ៉ាងដីនៅតំបន់នោះជាដីប្រភេទស្រែប្រាំង នឹងមិនមែនជាដីព្រៃលិចទឹកនោះទេ។ លោកបន្តថា នេះជាគោលដៅអភិវឌ្ឍន៍មួយក្នុងស្រុកតំបែរ ព្រោះអាចឱ្យប្រជាពលរដ្ឋរស់នៅតំបន់នោះមានការងារធ្វើ។ ដោយឡែក នាយខណ្ឌរដ្ឋបាលជលផល ខេត្តកំពង់ចាម បានបញ្ជាក់ថាទីនោះគឺពិតជាដែននេសាទ ដែលនៅរដូវទឹកជំនន់ ទន្លេមេគង្គបានហូរចូលតាមព្រែកឆ្លងបំពេញបឹងនោះ និងថាលោកបានបញ្ជូនរបាយការណ៍...ទៅអធិការដ្ឋានជលផលទន្លេមេគង្គរួចហើយ។

## ៣. កិច្ចប្រជុំនៅសាលារាជធានី លើដំណោះស្រាយពាក្យបណ្តឹងប្រអប់សំបុត្រគណនេយ្យភាព

តាមកាសែត ***នគរវត្ត*** ចេញផ្សាយថ្ងៃទី១០ ឧសភា បានឱ្យដឹងថា កាលពីថ្ងៃទី៩ ឧសភា នៅសាលារាជធានីភ្នំពេញ មានការរៀបចំកិច្ចប្រជុំមួយនៃក្រុមការងារគណនេយ្យភាពរាជធានីភ្នំពេញ លើពាក្យបណ្តឹងប្រជាពលរដ្ឋតាមរយៈប្រអប់សំបុត្រគណនេយ្យភាព ដោយមានការចូលរួមពីឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានី និងសមាសភាពក្រុមការងារគណនេយ្យភាពរាជធានីភ្នំពេញ មន្ត្រីសាលារាជធានី មន្ទីរមួយចំនួន ចៅសង្កាត់ អង្គការក្រៅរដ្ឋាភិបាល និងតំណាងក្រុមហ៊ុន សរុបចំនួន១៣រូប។ ថ្លែងក្នុងឱកាសនោះ លោក ម៉ៅ បូរ៉ា នាយកទីចាត់ការផែនការនិងវិនិយោគ លើកឡើងថា ក្នុងឆ្នាំ ២០១១ គិតត្រឹមខែមេសា សរុបបណ្តឹងដែលទទួលបានតាមរយៈប្រអប់សំបុត្រគណនេយ្យភាពមានចំនួន៤០ករណី ក្នុងនោះមានតែ២០ករណីទេ បានលើកយកមកដោះស្រាយ ព្រោះករណីខ្លះគ្មានមូលដ្ឋានច្បាស់លាស់ និងខ្លះមិនទាន់បានទទួលព័ត៌មានពីអាជ្ញាធរពាក់ព័ន្ធ។ ឯកឧត្តមអភិបាលរាជធានីភ្នំពេញបានថ្លែងផងដែរក្នុងន័យជំរុញឱ្យសង្កាត់ ខណ្ឌ និងមន្ទីរ ចាំបាច់ត្រូវរាយការណ៍ បន្ទាប់ពីដោះស្រាយបណ្តឹងទាំងនោះដើម្បីមានមូលដ្ឋានឆ្លើយតប និងចំណាត់ការបន្ត។ គួរបញ្ជាក់ថា ប្រអប់សំបុត្រគណនេយ្យភាព មានដាក់នៅសាលារាជធានីភ្នំពេញ សាលាខណ្ឌ

ទាំង៨ មន្ទីរជំនាញ ទីផ្សារ និងតាមបណ្តារអង្គការនានា សរុបចំនួន ១៣២ ប្រអប់ ហើយរាល់ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋត្រូវបែងចែកជាបីប្រភេទ ទី(១) ពាក្យបណ្តឹងពីការអភិវឌ្ឍន៍ដូចជាសុំពង្រីកផ្លូវ និងដាក់ភ្លើងសញ្ញាចរាចរណ៍ ទី(២) ពាក្យបណ្តឹងពីបញ្ហាសន្តិសុខសណ្តាប់ធ្នាប់សង្គមដូចជាអំពើចោរកម្ម ការចតយានយន្តគ្មានសណ្តាប់ធ្នាប់ និង ទី(៣) ពាក្យបណ្តឹងការផ្តល់សេវាសាធារណៈ ដូចជាមន្ត្រីអាជ្ញាធរមូលដ្ឋានណាមួយមិនបំពេញភារកិច្ចតាមមុខងារឱ្យមានប្រសិទ្ធិភាព។